31. ...................... ជាដែនម៉ាញេទិចដែលខ្សែដែនជាបន្ទាត់ស្របៗគ្នា មានទិស ទិសដៅដូចគ្នា និងអាំងតង់ស៊ីតេស្មើគ្នាជានិច្ច(ស្មើគ្នាគ្រប់ចំណុចទាំងអស់) ។

a) ដែនម៉ាញេទិចឯកសណ្ឋាន
b) ដែនម៉ាញេទិច
c) ដែនអគ្គិសនី
d) កម្លាំងម៉ាញេទិច

32. ដែនម៉ាញេទិចឯកសណ្ឋានកើតមាន៖

a) នៅជុំវិញខ្សែចម្លងវង់
b) · នៅចន្លោះប៉ូលទាំងពីរនៃមេដែករាង U
c) នៅចន្លោះបូប៊ីន ហ៊ុម-ហ៊ុល
d) · នៅខាងក្នុងសូលេណូអ៊ីត

33. ចលនាផង់ផ្ទុកបន្ទុកអគ្គិសនីផ្លាស់ទីក្នុងដែនម៉ាញេទិចឯកសណ្ឋាន តើពេលណាវាមានចលនាត្រង់ស្មើ ?

a) $\overrightarrow{v} \perp \overrightarrow{B}$
b) $\overrightarrow{v}, \overrightarrow{B} = \theta$
c) $\overrightarrow{v} \parallel \overrightarrow{B}$

34. ចលនាផង់ផ្ទុកបន្ទុកអគ្គិសនីផ្លាស់ទីក្នុងដែនម៉ាញេទិចឯកសណ្ឋាន តើពេលណាវាមានចលនាវង់ស្មើ ?

a) $\overrightarrow{v} \parallel \overrightarrow{B}$
b) $\overrightarrow{v}, \overrightarrow{B} = \theta$
c) $\overrightarrow{v} \perp \overrightarrow{B}$

35. ចលនាផង់ផ្ទុកបន្ទុកអគ្គិសនីផ្លាស់ទីក្នុងដែនម៉ាញេទិចឯកសណ្ឋាន តើពេលណាវាមានចលនាលើគន្លងស្បៀរ៉ាល់?

a) $\overrightarrow{v}, \overrightarrow{B} = \theta$
b) $\overrightarrow{v} \parallel \overrightarrow{B}$
c) $\overrightarrow{v} \perp \overrightarrow{B}$

36. ...............ជាបាតុភូតដែលកើតមានឡើងនៅពេលដែលមានបម្រែបម្រួលដែនម៉ាញេទិច ឬ បម្រែបម្រួលភ្លុចម៉ាញេទិចកើតមានក្នុងបូប៊ីន ។

a) បាតុភូតអូតូអាំងឌុចស្យុង
b) អាំងឌុចស្យុងម៉ាញេទិច
c) ចរន្តអាំងឌី
d) បាតុភូតអាំងឌុចស្យុងអេឡិចត្រូម៉ាញេទិច

LIVEWORKSHEETS